

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល

# កញ្ចប់សម្ភារៈអាហារល្អ



សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល

# កញ្ចប់សម្ភារៈអាហារល្អ

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលអំពីកញ្ចប់សម្ភារៈអាហារល្អនេះត្រូវបានបង្កើតឡើងលើកទីមួយ ក្នុងឆ្នាំ២០០៩ ហើយឯកសារនេះគឺជាការត្រួតពិនិត្យលើកទីពីរដែលមានការកែសម្រួល និងធ្វើបច្ចុប្បន្នកម្ម នៅចុងឆ្នាំ២០១៤។

ការត្រួតពិនិត្យលើកទីមួយ បង្កើតឡើងក្រោមទឹកចិត្តសប្បុរសរបស់ប្រជាជនអាមេរិកតាមរយៈមូលនិធិ របស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID) និងមូនិធិសកលប្រយុទ្ធនឹងជំងឺអេដស៍ របេង និងជំងឺគ្រុនចាញ់ (GFATM) ។

ការត្រួតពិនិត្យលើកទីពីរនៃសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះបានទទួលការគាំទ្រដោយ កម្មវិធីស្បៀងអាហារពិភពលោកប្រទេសកម្ពុជារបស់អង្គការសហប្រជាជាតិ ដែលមានការកែសម្រួល ការធ្វើបច្ចុប្បន្នកម្មបកប្រែ បោះពុម្ព និងផ្សព្វផ្សាយ។

ការត្រួតពិនិត្យលើកទីពីរនៃសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួលនេះអាចចម្លងបាន និងចែកជូន តាមតម្រូវការក្នុងករណីដែលមានការបញ្ជាក់ពីប្រភពច្បាស់លាស់។

បោះពុម្ពលើកទីមួយ ឆ្នាំ២០០៩

ត្រួតពិនិត្យ និងបោះពុម្ពឡើងវិញ ឆ្នាំ២០១៤ (លើកទី ២)

ត្រួតពិនិត្យឡើងវិញ ឆ្នាំ២០១៧ (លើកទី ៣)

# អារម្ភកថា

សមាហរណកម្មនៃកម្មវិធីអេដស៍ និងអាហារូបត្ថម្ភនៅក្នុងវិស័យសុខាភិបាលនៅកម្ពុជាត្រូវបានកំណត់ជាវិស័យអាទិភាព នៅក្នុងយុទ្ធសាស្ត្រជាតិអាហារូបត្ថម្ភឆ្នាំ ២០០៩-២០១៥ និង គំរោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យ ឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៣ (២០១១-២០១៥)។ សមាហរណកម្មនេះត្រូវបានធ្វើឡើងដោយអនុលោមតាមការទទួលស្គាល់ជាសកល នូវតួនាទីដ៏សំខាន់របស់អាហារូបត្ថម្ភទៅលើសុខភាព និងសុខមាលភាពរបស់បុគ្គលម្នាក់ៗ ជាពិសេសអ្នកដែលរស់នៅជាមួយមេរោគអេដស៍។

មេរោគអេដស៍ និងអាហារូបត្ថម្ភមានទំនាក់ទំនងដែលមិនអាចកាត់ផ្តាច់បាន។ មេរោគអេដស៍ធ្វើឲ្យមានផលប៉ះពាល់ទៅលើស្ថានភាពអាហារូបត្ថម្ភរបស់អ្នកផ្ទុកមេរោគនេះ រួមទាំង កុមារដែលរស់នៅជាមួយមេរោគអេដស៍ កុមារកំព្រា និងក្រុមកុមារងាយរងគ្រោះផងដែរ។ មេរោគអេដស៍ប៉ះពាល់ដល់ស្ថានភាពអាហារូបត្ថម្ភ ដោយបំផ្លាញនូវប្រព័ន្ធការពាររាងកាយ និងសមត្ថភាពបឺតស្រូបយកសារជាតិចិញ្ចឹមរបស់សារពាង្គកាយ។ កង្វះអាហារូបត្ថម្ភបន្តធ្វើអោយប្រព័ន្ធការពាររាងកាយកាន់តែចុះខ្សោយ ដែលបង្កើននូវអត្រាឆ្លងជំងឺឱកាសនិយមផ្សេងៗ។ ជាមួយនឹងកង្វះអាហារូបត្ថម្ភដែលមានស្រាប់ អ្នកផ្ទុកមេរោគអេដស៍ មានការលំបាកក្នុងការរក្សាសុខភាពខ្លួនឯងបានល្អ មានការធ្លាក់ចុះផ្នែកសេដ្ឋកិច្ច និងប្រាក់ចំណូល និង មិនអាចជួយសម្រាលបន្ទុកដល់ក្រុមគ្រួសារ ជាពិសេស ដល់កូនៗរបស់ពួកគាត់បានទេ។

ការគាំទ្រផ្នែកអាហារូបត្ថម្ភគឺជាសមាសធាតុដ៏សំខាន់ និងទូលំទូលាយបំផុតក្នុងការបង្ការ ការថែទាំ និងការព្យាបាលដល់អ្នកផ្ទុកមេរោគអេដស៍។ ការផ្តល់នូវការវាយតម្លៃ ការអប់រំ ការប្រឹក្សា និងការគាំទ្រទៅលើផ្នែកអាហារូបត្ថម្ភ អាចជួយលើកតម្កើងស្ថានភាពអាហារូបត្ថម្ភ ធានាឲ្យបាននូវការបរិភោគគ្រប់គ្រាន់ បង្កើនប្រសិទ្ធិភាពការងារ ការអនុវត្តបានខ្ជាប់ខ្ជួនក្នុងការព្យាបាល និងបង្កើនគុណភាពជីវិតរបស់បុគ្គលម្នាក់ៗ ហើយក៏ដើម្បីស្វែងយល់ និងដោះស្រាយនូវបញ្ហាអាហារូបត្ថម្ភដែលប្រឈមមុខដោយអ្នករស់នៅជាមួយមេរោគអេដស៍។

ដោយយល់ឃើញអំពីសារៈសំខាន់របស់អាហារូបត្ថម្ភ នៅក្នុងការថែទាំឲ្យបានទូលំទូលាយដល់អ្នករស់នៅជាមួយមេរោគអេដស៍ «កញ្ចប់សម្ភារៈអាហារល្អ» ជាមួយនឹងសៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល ត្រូវបានរៀបរៀងឡើងសម្រាប់បុគ្គលិកឯកទេសសុខាភិបាល បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ក្រុមការងារថែទាំតាមផ្ទះ និងក្រុមជួយខ្លួនឯង ដែលផ្តល់ការអប់រំ និងគាំទ្រផ្នែកអាហារូបត្ថម្ភ ដល់មនុស្សពេញវ័យ កុមារ និងសហគមន៍ដែលរស់នៅជាមួយអ្នកផ្ទុក និងរងការប៉ះពាល់ដោយសារមេរោគអេដស៍។

ក្រសួងសុខាភិបាលសូមគាំទ្រដល់ «កញ្ចប់សម្ភារៈអាហារល្អ» នេះ ដែលជាឧបករណ៍ដ៏ចាំបាច់មួយ សម្រាប់ការកសាងសមត្ថភាពរបស់អ្នកផ្តល់ប្រឹក្សា ដើម្បីផ្តល់ការគាំទ្រផ្នែកអាហារូបត្ថម្ភដល់អ្នករស់នៅជាមួយមេរោគអេដស៍នៅកម្ពុជា ឲ្យបានប្រកបដោយប្រសិទ្ធិភាព។

រាជធានីភ្នំពេញ ថ្ងៃទី...០៦... ខែ........ ឆ្នាំ ២០១៤

**សាស្ត្រាចារ្យ អេង ហួត**

រដ្ឋលេខាធិការក្រសួងសុខាភិបាល